# Living the Lotus 10

## Buddhism in Everyday Life

2026
VOL. 253
















Thank you for reading *Living the Lotus* every month. Thanks to your support, Living the Lotus is celebrating its 21st anniversary this month. We would like to express our heartfelt gratitude to everyone who has supported us in so many ways.

In conjunction with the recent redesign of the Rissho Kosei-kai English website, *Living the Lotus* will transition from its current PDF newsletter format to a new web magazine format starting in November.

This month's issue will be the final PDF edition, but *Living the Lotus* will continue to bring you the President's Message and a variety of articles on how to apply Buddhism to daily life.

We hope you will continue to enjoy *Living the Lotus* by visiting its page on our website.
















**Living the Lotus**
**Vol. 252 (September 2026)**

Senior Editor: Takashi Maeda
Editor: Sachi Mikawa
Copy Editor: Penn Setharin

*Living the Lotus* is published monthly
By Rissho Kosei-kai International,
Fumon Media Center, 2-7-1 Wada,
Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp

រីហ្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។
អង្គការរីហ្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិក រីហ្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.

President's Messsage

# រស់ និងស្លាប់ នៅក្នុងក្របខ័ណ្ឌនៃព្រះធម៌ដ៏អស្ចារ្យ (១)

ដោយព្រះគ្រូនីវ៉ាណូ នីជីកុ
ព្រះប្រធានរីស្ហូក្កូសេកៃ



## ជម្នះលើ «សេចក្ដីស្លាប់»

"ចំណុចសំខាន់នៃការប្រតិបត្តិព្រះធម៌ក្នុងព្រះពុទ្ធសាសនាគឺការ«ឈានទៅឱ្យហួសពីឬការយកឈ្នះលើកើត ចាស់ ឈឺ ស្លាប់»"។ នេះគឺជាឃ្លាមួយដែលដកស្រង់ចេញពីការសម្ដែងព្រះធម៌របស់ស្ថាបនិកកៃសូសាម៉ាអំពីទស្សនៈរបស់ព្រះពុទ្ធសាសនាទៅលើជីវិតនិងសេចក្ដីស្លាប់របស់មនុស្ស។ ដោយសារតែ «សេចក្ដីស្លាប់» ជាព្រឹត្តិការណ៍ដ៏សំខាន់បំផុតមួយនៅក្នុងជីវិតរបស់មនុស្ស ការ «ឈានទៅឱ្យហួសពី» ឬការយកឈ្នះលើក្ដីកង្វល់ ការភ័យខ្លាច និងទុក្ខវេទនាដែលពាក់ព័ន្ធនឹងវា (ដូចជាថាតើនឹងមានអ្វីកើតឡើងក្រោយពេលស្លាប់ឬក៏ថាខ្ញុំខ្លាចស្លាប់ណាស់ ខ្ញុំមិនចង់ស្លាប់ទេដែលជាការភ័យខ្លាចចំពោះសេចក្ដីស្លាប់) គឺជាផ្នែកដ៏សំខាន់មួយនៃមាគ៌ាព្រះពុទ្ធសាសនា។ ការអប់រំកាយ និងចិត្ត ព្រមទាំងការប្រាថ្នានូវសុភមង្គលសម្រាប់ខ្លួនឯង និងអ្នកដទៃ ស្របពេលដែលសម្រេចបាននូវសន្តិភាពផ្លូវចិត្តគឺជាសេចក្ដីព្យាយាមនៅក្នុងមាគ៌ាព្រះពុទ្ធសាសនា។

ពាក់ព័ន្ធនឹងទស្សនៈ «រស់ និងស្លាប់» ដែលជាចំណុចសំខាន់មួយនៃមាគ៌ាព្រះពុទ្ធសាសនា ខ្ញុំព្រះករុណាអាត្មាភាពធ្លាប់បាននិយាយថាសេចក្ដីស្លាប់ថាគឺជាការវិលត្រឡប់ទៅកាន់ស្រុកកំណើតដែលមានឈ្មោះថា «មហាជីវិតដ៏អស្ចារ្យ»វិញផងម្យ៉ាងទៀតផ្អែកទៅលើសំណេររបស់សាស្ត្រាចារ្យសាជី ហារីអូ ដែលជារូបវិទ្យាទ្រឹស្ដីវិទូ ខ្ញុំព្រះករុណាអាត្មាភាពបានបង្ហាញពីទស្សនៈនៃជីវិតថាជីវិតរបស់យើងគឺជាអ្វីដែលផ្ជាប់ទៅជាខ្លួនមួយជាមួយនឹងចក្រវាល។ «បើនិយាយឱ្យជ្រុលបន្តិចទៅ គឺថាយើងរាល់គ្នាកំពុងរស់នៅជីវិតអមតៈជារៀងរាល់ថ្ងៃ»។

នៅពេលដែលយើងមើលទៅ «ជីវិត» ពីទស្សនៈចក្រវាល ដែលស្របនឹងការបង្រៀននៃព្រះធម៌បទុមសូត្រដែរ យើងនឹងឃើញថាយើងទាំងអស់គ្នារស់នៅ «ជីវិតអមតៈ» ដែលបន្តពីអតីតកាលចាប់តាំងពីការកកើតនៃចក្រវាលរហូតទៅដល់អនាគតកាល។

ប្រសិនបើយើងទទួលយកទស្សនៈនេះ សេចក្ដីស្លាប់នឹងមិនមែនជាអ្វីដែលត្រូវខ្លាចនោះទេ ហើយការថប់បារម្ភ និងការព្រួយបារម្ភទៅលើសេចក្ដីស្លាប់នឹងត្រូវបានបន្ធូរបន្ថយខ្លះ។

មីយ៉ាហ្សាវ៉ា គេនជី ជាកវីនិពន្ធម្នាក់ដែលប្រឈមនឹងសេចក្តីស្លាប់នៅនឹងមុខពិតៗហើយបានជម្នះលើទុក្ខវេទនានៃរស់និងស្លាប់តាមរយៈជំនឿទៅលើព្រះធម៌បទុមសូត្រដែលអធិប្បាយថាជីវិតរបស់ព្រះពុទ្ធអមតៈ។ នៅក្នុងកំណាព្យមួយដែលចាប់ផ្តើមដោយ "ខ្ញុំក៏នឹងស្លាប់ / ថ្ងៃនេះ ឬថ្ងៃស្អែក" គេនជីបានបើកបង្ហាញពីស្ថានភាពផ្លូវចិត្តរបស់គាត់ថា "ពេលខ្ញុំស្លាប់ទៅ ខ្ញុំនឹងត្រឡប់ទៅរកភាពទទេវិញ / ខ្ញុំនឹងមានអារម្មណ៍ជាខ្លួនឯងជាថ្មីម្តងទៀត / (សូមសង្ខេប) / ឈ្មោះនៃព្រះធម៌ដើមនោះមានឈ្មោះថាសទ្ធម្មបុណ្ឌរិកសូត្រ(ព្រះបទុមសូត្រ) "។ គាត់ជឿថាក្រោយពេលស្លាប់ យើងត្រឡប់ទៅចក្រវាលដែលជា "មហាជីវិតដ៏អស្ចារ្យ"ហើយនៅទីបំផុតក៏នឹងកើតជាថ្មីដូច ដែលបានបង្ហាញនៅក្នុងគម្ពីរសទ្ធម្មបុណ្ឌរិកសូត្រ(ព្រះបទុមសូត្រ) ។

តាមរយៈព្រះធម៌នៃគម្ពីរសទ្ធម្មបុណ្ឌរិកសូត្រ(ព្រះបទុមសូត្រ)គេនជីបានចាប់ភ្លឹកពីអត្ថិភាពផ្ទាល់ខ្លួនដែលរស់នៅ "ជីវិតអមតៈ" ហើយក៏បានស្រោចស្រង់ពីទុក្ខវេទនានៃជំងឺ។ គេនជី បានសរសេរបន្ថែមទៀតថា"រស់ក៏រស់ជីវិតនៃសទ្ធម្មបុណ្ឌ រិកសូត្រ(ព្រះបទុមសូត្រ) / ស្លាប់ក៏ស្លាប់ជីវិតនៃសទ្ធម្មបុណ្ឌរិកសូត្រ(ព្រះបទុមសូត្រ) ដែរ"។ មានន័យថាគាត់អាចទទួលយកយ៉ាងបានបទទាំង "ជីវិត" ដែលមានជំងឺ និង "សេចក្តីស្លាប់"ដែលកំពុងតែខិតមកជិតគាត់ថាជាធម៌ដ៏អស្ចារ្យ(សច្ចធម៌) ។

## យើងទាំងឡាយរស់នៅ "ជីវិតអមតៈ"

មីយ៉ាហ្សាវ៉ា គេនជី បានសរសេរកំណាព្យនេះ (នៅខែកុម្ភៈ ឆ្នាំ 1929) ប្រហែលជាបួនឆ្នាំមុនមរណភាពរបស់គាត់ គឺនៅពេលដែលគាត់មានអាយុ 33 ឆ្នាំ។ ជាការកម្រណាស់ចំពោះយុវជនដែលមានទស្សនៈបែបនេះអំពីជីវិត និងសេចក្តីស្លាប់ទាំងនៅវ័យក្មេងបែបនេះ។ ជាការពិតឥតសង្ស័យថាទស្សនៈនេះទទួលឥទ្ធិពលពីការបង្រៀនប្រៀនប្រដៅនៃព្រះធម៌បទុមសូត្រ។

គ្មាននរណាម្នាក់ដឹងថាតើគេនឹងទៅណា ឬនឹងមានអ្វីកើតឡើងបន្ទាប់ពីស្លាប់ទៅនោះទេ។ យ៉ាងណាមិញនៅពេលដែលដឹងថាយើងបន្តរស់នៅ "ជីវិតអស់កល្បជានិច្ច" ទាំងឥឡូវនេះ និងក្រោយពេលស្លាប់វានឹងនាំមកឱ្យយើងនូវសេចក្តីស្ងប់ក្សេមក្សាន្តខាងផ្លូវចិត្ត ។ សេចក្តីអំណររបស់គេនជី នៅពេលដែលបានភពប្រសព្វនឹងព្រះធម៌បទុមសូត្រ គឺជាសេចក្តីអំណររបស់យើងរាល់គ្នាដែលមានជំនឿដូចគ្នាដែរ។

អារម្មណ៍ផ្ទាល់ខ្លួនរបស់ខ្ញុំព្រះករុណាអាត្មាភាពផ្ទាល់ពីមុនរហូតមកដល់ឥឡូវនៅតែមិនប្រែប្រួលដែលគិតថា "ប្រសិនបើខ្ញុំព្រះករុណាអាត្មាភាពអាចស្លាប់បែបកែសូសាម៉ាបានមិនដឹងជាល្អយ៉ាងណាទេ" ដោយបានឃើញផ្ទាល់នឹងភ្នែកនូវការវិលត្រឡប់ដ៏ក្សេមក្សាន្តនៃព្រះស្ថាបនិកកែសូសាម៉ាទៅកាន់ស្រុកកំណើតនៃជីវិត។ ខ្ញុំព្រះករុណាអាត្មាភាពអាចទទួលយកសេចក្តីស្លាប់ដោយអារម្មណ៍ស្ងប់ស្ងាត់ហើយក៏សូមអរគុណចំពោះការស្រាវជ្រាវបន្តបន្ទាប់ទៅលើជីវិតរបស់បុព្វការីរៀមច្បងទាំងឡាយ និងអំណាចនៃជំនឿផងដែរ។

យ៉ាងណាមិញ សេចក្តីស្លាប់នឹងចូលមកដល់មនុស្សគ្រប់ៗគ្នាមិនថាគេមិនថាយើង។ ប្រហែលជាគ្មានសេចក្តីស្លាប់ណាដែលមនុស្សអាចទទួលយកដោយបានបទនោះទេ។ នោះហើយជាមូលហេតុដែល «កើតចាស់ឈឺស្លាប់»បានទៅជាប្រធានបទសំខាន់មួយក្នុងជីវិត។ ដោយសារតែមនុស្សគ្រប់គ្នានឹងត្រូវប្រឈមមុខនឹងសេចក្តីស្លាប់ការក្រេបជញ្ជក់រសជាតិនៃសេចក្តីរីករាយនៃការរស់នៅបច្ចុប្បន្ន និងការរស់នៅ «ពេលឥឡូវនេះ» ដោយសុខដុមរមនាជាមួយអ្នកដទៃជាច្រើន គឺជាសុភមង្គលដ៏អស្ចារ្យបំផុត។

ដូច្នេះនៅក្នុងលំហូជាបន្តបន្ទាប់ឥតដាច់នៃ«ជីវិតអមតៈ»ដែលមានជីវិតក្នុងជាតិនេះមួយដែរវាគ្មានហេតុផលអ្វីដែលយើងត្រូវទទួលរែកពុនទុក្ខវេទនានៃកើតចាស់ឈឺស្លាប់នោះទេ។ខ្ញុំព្រះករុណាអាត្មាភាពនឹងពិចារណារឿងនេះម្តងទៀតនៅពេលក្រោយ។

『កូសេ』 លេខខែតុលាឆ្នាំ២០២៦



# Rissho Kosei-kai International

## Make Every Encounter Matter

## A Global Buddhist Movement




### Information about local Dharma centers

facebook

X

We welcome comments on our newsletter Living the Lotus: living.the.lotus.rk-international@kosei-kai.or.jp